# ព្រះរាជក្រឹត្យ

នស/រកត/១២១៩/១៧៦៤

## ស្តីពី

## ការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រឹត្យ (see heading below)

## ជំពូកទី២
## សមាជិកនៃរ.ប.ស.ក.
### ផ្នែកទី១
### សមាជិកបណ្ឌិតសភានៃរ.ប.ស.ក.

**មាត្រា៥ .-**

**រ.ប.ស.ក.**មានសមាជិកបណ្ឌិតសភា៣(បី)ប្រភេទះ

១-**សមាជិកពេញសិទ្ធិ** ជាបញ្ញវន្តដែលមានសញ្ញាបត្របណ្ឌិតដែលសម្រេចបាននូវការរកឃើញថ្មីក្នុងវិស័យស្រាវជ្រាវវិទ្យាសាស្ត្រឬដែលសម្រេចបាននូវស្នាដៃនវានុវត្តបច្ចេកទេសឬបច្ចេកវិទ្យាដែលផ្តល់គុណប្រយោជន៍ធំធេងដល់សង្គមជាតិនិងមានបទពិសោធន៍ការងារយ៉ាងតិច១០(ដប់)ឆ្នាំ ក្រោយជាប់សញ្ញាបត្របណ្ឌិតឬមានគុណសម្បត្តិធំធេងក្នុងកិច្ចការរៀបចំនិងដឹកនាំអនុវត្តគោលនយោបាយអភិវឌ្ឍន៍សង្គមជាតិ។ សមាជិកពេញសិទ្ធិត្រូវបានជ្រើសរើសចេញពីក្នុងចំណោមសមាជិកបម្រុងដោយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។ សមាជិកពេញសិទ្ធិមានចំនួនកំណត់មិនលើសពី៧៤(ចិតសិបប្រាំបួន)រូបនិងត្រូវតែងតាំងដោយព្រះរាជក្រឹត្យហើយទទួលគោរមងារជាបណ្ឌិតសភាចារ្យ។

២-សមាជិកបម្រុង ជាបញ្ញវន្តដែលមានសញ្ញាបត្របណ្ឌិតដែលកំពុងបំពេញការងារក្នុងក្របខ័ណ្ឌឯកទេសរបស់ខ្លួនយ៉ាងតិច១០(ដប់)ឆ្នាំ ក្រោយពេលជាប់សញ្ញាបត្របណ្ឌិតនិងបានបោះពុម្ពផ្សាយស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រសង្គមឬវិទ្យាសាស្ត្រពិតជាសាធារណៈយ៉ាងតិច៣(បី)ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។ សមាជិកបម្រុងត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យនិងត្រូវតែងតាំងដោយអនុក្រឹត្យ។

៣-សមាជិកសមាគមិក ជាបញ្ញវន្តដែលមានសញ្ញាបត្របណ្ឌិតដែលបានជួយឧបត្ថម្ភចំពោះការពង្រីកវិទ្យាសាស្ត្រសង្គមនិងវិទ្យាសាស្ត្រពិត សម្រាប់គុណប្រយោជន៍ដល់ប្រទេសកម្ពុជា។ សមាជិកសមាគមិកត្រូវបានជ្រើសរើសចេញពីក្នុងចំណោមជនជាតិខ្មែរនិងជនជាតិបរទេសដោយក្រុមប្រឹក្សាបណ្ឌិតសភាចារ្យនិងតាមសំណើពីសមាជិកពេញសិទ្ធិណាម្នាក់ឬពីសាមីខ្លួនដោយមានការធានាពីសមាជិកពេញសិទ្ធិយ៉ាងតិចចំនួន៣(បី)រូបនិងត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា៦ .-**

សមាជិកពេញសិទ្ធិ សមាជិកបម្រុង និងសមាជិកសមាគមិក ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនដោយករណីមរណភាពឬដោយការសុំលាឈប់។

**មាត្រា៧ .-**

លក្ខន្តិកៈសមាជិកបណ្ឌិតសភានៃ**រ.ប.ស.ក.**ត្រូវកំណត់ដោយអនុក្រឹត្យ។

### ផ្នែកទី២
### សមាជិកកិត្តិយសនិងសមាជិកឆ្លើយឆ្លង

**មាត្រា៨ .-**

សមាជិកកិត្តិយសជាជនជាតិខ្មែរឬបរទេសដែលបានចូលរួមចំណែកឧបត្ថម្ភនិងគាំទ្រជាប្រចាំចំពោះការស្រាវជ្រាវវិទ្យាសាស្ត្រដែលមានគុណប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា។

សមាជិកកិត្តិយសត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា៩ .-**

សមាជិកឆ្លើយឆ្លងជាជនជាតិខ្មែរឬបរទេសរស់នៅក្នុងឬក្រៅប្រទេស ដែលភ្ជាប់ទំនាក់ទំនងរវាង **រ.ប.ស.ភ.** និងស្ថាប័នសិក្សាស្រាវជ្រាវជាតិនិងអន្តរជាតិជាប្រចាំ។

សមាជិកឆ្លើយឆ្លងត្រូវតែងតាំងដោយអនុក្រឹត្យ។

## ជំពូកទី៣
## ការដឹកនាំនិងការគ្រប់គ្រង
### ផ្នែកទី១
### ក្រុមប្រឹក្សាភិបាលរបស់រ.ប.ស.ភ.

**មាត្រា១០ .-**

**រ.ប.ស.ភ.**ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលជាអង្គការដឹកនាំខ្ពស់បំផុតនិងមានបេសកកម្ម តម្រង់ទិសការអនុវត្តនិងត្រួតពិនិត្យសកម្មភាពការងាររបស់**រ.ប.ស.ភ.** ក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

**មាត្រា១១ .-**

ក្រុមប្រឹក្សាភិបាលនៃ**រ.ប.ស.ភ.**មានសមាសភាព ដូចតទៅ៖

| | | |
|---|---|---|
| - តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | ១រូប | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| - តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ១រូប | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | ១រូប | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | ១រូប | សមាជិក |
| - ប្រធាន**រ.ប.ស.ភ.** | | សមាជិក |
| - តំណាងបុគ្គលិកនៃ**រ.ប.ស.ភ.** | ១រូប | សមាជិកស្វ័យប្រវត្តិ។ |

ក្រុមប្រឹក្សាភិបាលនៃ**រ.ប.ស.ភ.**ត្រូវបង្កើតក្នុងរយៈពេលយ៉ាងយូរ១(មួយ)ខែ ក្រោយពីកាលបរិច្ឆេទចូលជាធរមាននៃព្រះរាជក្រឹត្យនេះ។

**មាត្រា១២ .-**

តំណាងបុគ្គលិកនៃ**រ.ប.ស.ភ.**១(មួយ)រូបជាសមាជិកស្វ័យប្រវត្តិនៃក្រុមប្រឹក្សាភិបាលដែលត្រូវបាន ជ្រើសរើសដោយការបោះឆ្នោតពីក្នុងចំណោមបុគ្គលិកអចិន្ត្រៃយ៍ សម្រាប់អាណត្តិ៣(បី)ឆ្នាំ។ តំណាងបុគ្គលិក ត្រូវក្លាយជាសមាជិកស្វ័យប្រវត្តិនៃក្រុមប្រឹក្សាភិបាលចាប់ពីថ្ងៃជាប់ឆ្នោត ដោយមិនចាំបាច់មានការតែងតាំង ឡើយ។ នៅពេលចប់អាណត្តិឬលាឈប់ពីការងារ តំណាងបុគ្គលិកនេះត្រូវបាត់បង់សមាជិកភាពក្រុមប្រឹក្សា ភិបាលដោយស្វ័យប្រវត្តិ។ តំណាងបុគ្គលិកនេះត្រូវបានជ្រើសរើសដោយការបោះឆ្នោតដែលប្រព្រឹត្តទៅតាម បែបបទប្រជាធិបតេយ្យ។ អ្នកមានសិទ្ធិបោះឆ្នោតសម្រាប់៖

ក-អាណត្តិដំបូងនៃក្រុមប្រឹក្សាភិបាលគឺបុគ្គលិកអចិន្ត្រៃយ៍។

ខ-អាណត្តិនៃក្រុមប្រឹក្សាភិបាលបន្តបន្ទាប់ទៀតគឺបុគ្គលិកទាំងអស់ដែលមានសិទ្ធិបោះឆ្នោតតាមការ ជាសម្រេចរបស់ប្រធាន**រ.ប.ស.ភ.**។

តំណាងនេះ ត្រូវជ្រើសរើសពីក្នុងចំណោមបុគ្គលិកអចិន្ត្រៃយ៍ ដោយមានសំឡេងគាំទ្រភាគច្រើនដាច់ខាត ស្របតាមលក្ខខណ្ឌវិនិច្ឆ័យ ដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ ហើយមានអាយុយ៉ាងតិច ២៥(ម្ភៃប្រាំ)ឆ្នាំ និងយ៉ាងច្រើន៥៥(ហាសិបប្រាំ)ឆ្នាំ
- បម្រើការងារយ៉ាងតិច៥(ប្រាំ)ឆ្នាំ ដោយយកចិត្តទុកដាក់ក្នុងការការពារផលប្រយោជន៍ឱ្យបុគ្គលិកទាំងអស់និង**រ.ប.ស.ក.**
- មានកិរិយាមារយាទល្អ
- ពុំធ្លាប់ទទួលការផ្ដន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងទំនុកចិត្តនិងសមត្ថភាពប្រកបវិជ្ជាជីវៈ
- មានសមត្ថភាពនិងបទពិសោធន៍វិជ្ជាជីវៈគ្រប់គ្រាន់ តាមសំណូមពរនិងលក្ខខណ្ឌនៃការងាររបស់**រ.ប.ស.ក.**។

នីតិវិធីសម្រាប់ការបោះឆ្នោតតំណាងបុគ្គលិកជាសមាជិកស្វ័យប្រវត្តិនៃក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិនីមួយៗនៃ**រ.ប.ស.ក.**ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន**រ.ប.ស.ក.**។

ក្រៅពីប្រធាន**រ.ប.ស.ក.** និងសមាជិកស្វ័យប្រវត្តិនៃក្រុមប្រឹក្សាភិបាល សមាសភាពក្រុមប្រឹក្សាភិបាលដទៃទៀតត្រូវមានអាណត្តិ៣(បី)ឆ្នាំ ដែលត្រូវបានតែងតាំងនិងបញ្ចប់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ស្ថាប័នដែលសមាជិកនោះតំណាងឱ្យ។ អាណត្តិនេះអាចបន្តសាជាថ្មីទៀតបានដោយអនុក្រឹត្យ ប៉ុន្តែមិនត្រូវលើសពី២(ពីរ)អាណត្តិឡើយ។

**មាត្រា១៣ .-**

សមាជិកក្រុមប្រឹក្សាភិបាលត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការឬឥស្សរជនដែលមានលក្ខណសម្បត្តិ និងបទពិសោធន៍ ដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- បម្រើការងារយ៉ាងតិច៥(ប្រាំ)ឆ្នាំ
- ពុំធ្លាប់ទទួលការផ្ដន្ទាទោសពីបទមជ្ឈិមឬបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងទំនុកចិត្តនិងសមត្ថភាពប្រកបវិជ្ជាជីវៈ
- មានសមត្ថភាពជំនាញនៅក្នុងវិស័យពាក់ព័ន្ធ ជាអាទិ៍ រដ្ឋបាល សង្គមកិច្ច សុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស។

**មាត្រា១៤ .-**

សមាជិកភាពក្រុមប្រឹក្សាភិបាលអាចត្រូវបានបញ្ចប់មុនអាណត្តិតាមសំណើរបស់ក្រសួង ស្ថាប័នតំណាង ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ មានជាអាទិ៍ បាត់បង់ភាពស្របច្បាប់ជាតំណាងក្រសួង ស្ថាប័ន តំណាងបុគ្គលិករបស់**រ.ប.ស.ក.** ទទួលមរណភាព សុំលាឈប់ជាលាយលក្ខណ៍អក្សរ [illegible]ទៅវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬត្រូវបានផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ។

ក្រុមប្រឹក្សាភិបាលត្រូវបន្តនិរន្តរភាពការងាររបស់ខ្លួនរហូតដល់មានការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលថ្មី។ ក្រុមប្រឹក្សាភិបាលអាណត្តិថ្មីត្រូវតែងតាំងយ៉ាងយូរបំផុត១(មួយ)ខែ ក្រោយការបញ្ចប់អាណត្តិ

ក្រុមប្រឹក្សាភិបាលចាស់។ មុនការបញ្ចប់អាណត្តិក្រុមប្រឹក្សាភិបាល ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវរៀបចំសំណើទៅក្រសួង ស្ថាប័នតំណាងពាក់ព័ន្ធ ដើម្បីចាត់បញ្ជូនបេក្ខភាពសមាជិកក្រុមប្រឹក្សាភិបាលសម្រាប់អាណត្តិថ្មី។ ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវទទួលខុសត្រូវលើភាពយឺតយ៉ាវនៃការស្នើតែងតាំងក្រុមប្រឹក្សាភិបាល។ ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនីមួយៗត្រូវមានបញ្ជាក់អំពីអាណត្តិដែលសមាជិកនោះត្រូវទទួល។

សមាជិកក្រុមប្រឹក្សាភិបាលថ្មីដែលត្រូវបានតែងតាំងជំនួសកន្លែងទំនេរ ស្របតាមលក្ខខណ្ឌខាងលើមានអាណត្តិត្រឹមអាណត្តិដែលនៅសល់របស់សមាជិកក្រុមប្រឹក្សាភិបាលនោះ។

មុខងារជាប្រធានក្រុមប្រឹក្សាភិបាលនៃ**រ.ម.ស.ក.**មានវិសមិតភាពជាមួយមុខងារជាប្រធាន**រ.ម.ស.ក.**។

លើកលែងតែប្រធានក្រុមប្រឹក្សាភិបាល មុខងារជាសមាជិកក្រុមប្រឹក្សាភិបាល មានវិសមិតភាពមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា។

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាសមាជិកក្រុមប្រឹក្សាភិបាលត្រូវជាបន្ទុករបស់**រ.ម.ស.ក.** លើកលែងតែករណីដែលសមាជិកនោះបានប្រព្រឹត្តកំហុសដោយចេតនាឬដោយធ្វេសប្រហែសធ្ងន់ធ្ងរ។

សមាជិកនីមួយៗនៃក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។

សមាជិកក្រុមប្រឹក្សាភិបាលមានកាតព្វកិច្ច ដូចខាងក្រោម៖

- ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល
- ត្រូវប្រកាន់ខ្ជាប់នូវគោលជំហរាយការណ៍ជាប្រចាំពីសកម្មភាពការងារក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួន ជូនក្រសួង ស្ថាប័នដែលខ្លួនតំណាងឱ្យ
- ត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈ គោរពវិន័យ និងបទបញ្ជាផ្ទៃក្នុងរបស់**រ.ម.ស.ក.**។

**មាត្រា១៥ .-**

សមាសភាពក្រុមប្រឹក្សាភិបាលអាចទទួលបានលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ តាមគោលការណ៍កំណត់ជាធរមាន។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាសភាពក្រុមប្រឹក្សាភិបាលនៃ**រ.ម.ស.ក.**ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

តាមសំណើរបស់ក្រសួង ស្ថាប័នតំណាង រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចផ្អាកការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗខាងលើ ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ ពុំគោរពតាមអាណត្តិរបស់ខ្លួន ដូចជា៖

- ក្រមសីលធម៌វិជ្ជាជីវៈនិងមនសិការវិជ្ជាជីវៈ
- បទបញ្ជាផ្ទៃក្នុងនិងបទប្បញ្ញត្តិរបស់**រ.ម.ស.ក.**
- តួនាទីនិងភារកិច្ចនៅក្នុងក្រុមប្រឹក្សាភិបាល
- កាតព្វកិច្ចរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួនជូនក្រសួង ស្ថាប័នដែលសមាជិកក្រុមប្រឹក្សាភិបាលនោះតំណាងឱ្យ។

ប្រធានក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជនដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល ដែលមាន

បទពិសោធន៍ លើវិស័យពាក់ព័ន្ធ ជាអាទិ៍ ច្បាប់ រដ្ឋបាលសាធារណៈ សង្គមកិច្ច សុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស និងតំណាងដៃគូអភិវឌ្ឍនានាឱ្យចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលបាន។ ឥស្សរជនទាំងនោះមានសិទ្ធិផ្ដល់មតិ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។

**មាត្រា១៦ .-**

ក្រុមប្រឹក្សាភិបាលមានភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យនិងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលមធ្យមនិងរយៈពេលវែងរបស់**រ.ប.ស.ក.**
- ពិនិត្យនិងអនុម័តគម្រោងថវិកានិងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់**រ.ប.ស.ក.**
- ពិនិត្យនិងអនុម័តរបាយការណ៍គ្រប់គ្រង របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈរបស់**រ.ប.ស.ក.**
- ពិនិត្យនិងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់**រ.ប.ស.ក.** និងក្រមសីលធម៌វិជ្ជាជីវៈ
- កំណត់ការរៀបចំរចនាសម្ព័ន្ធនិងភារកិច្ចទូទៅរបស់អង្គភាពចំណុះរបស់**រ.ប.ស.ក.**
- ជំរុញដំណើរការរបស់គណៈកម្មាធិការនិងគណៈកម្មការដែលបង្កើតឡើងដោយព្រះរាជក្រឹត្យស្ដីពីការបង្កើត**រ.ប.ស.ក.** ព្រមទាំងបង្កើតគណៈកម្មាធិការនិងគណៈកម្មការនានាតាមការចាំបាច់
- កំណត់នីតិវិធីនៃការជ្រើសរើសបុគ្គលិក ការដំឡើងឋានន្តរស័ក្តិឬការផ្ដល់លាភការ និងប្រាក់ឧបត្ថម្ភផ្សេងៗ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ពិនិត្យនិងអនុម័តលើសំណើសុំរបស់ប្រធាន**រ.ប.ស.ក.** ក្នុងការកំណត់ក្របខ័ណ្ឌ និងចំនួនបុគ្គលិកប្រចាំឆ្នាំ
- ធ្វើការវាយតម្លៃលើលទ្ធផលសម្រេចបានប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ព្រមទាំងលើកវិធានការកែតម្រូវសម្រាប់អនុវត្តបន្ត។

**មាត្រា១៧ .-**

យ៉ាងយូរ១(មួយ)ខែក្រោយការបង្កើតក្រុមប្រឹក្សាភិបាល ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូងដែលរបៀបវារៈសំខាន់គឺការរៀបចំសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ**រ.ប.ស.ក.**ដែលក្នុងនោះត្រូវបញ្ជាក់ពីរចនាសម្ព័ន្ធនិងភារកិច្ចទូទៅរបស់អង្គភាពចំណុះនៃ**រ.ប.ស.ក.** នោះ។

ក្រុមប្រឹក្សាភិបាលនៃ**រ.ប.ស.ក.**មានរបបប្រជុំសាមញ្ញប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំវិសាមញ្ញ តាមគំនិតផ្ដួចផ្ដើមរបស់ប្រធានក្រុមប្រឹក្សាភិបាលឬតាមការស្នើសុំពីសមាជិកក្រុមប្រឹក្សាភិបាលចំនួន២ភាគ៣ឬពីប្រធាន**រ.ប.ស.ក.** តាមការចាំបាច់។

សម្រាប់ការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ចាំបាច់ត្រូវដាក់បញ្ចូលរបៀបវារៈទាក់ទងនឹងការអនុវត្តថវិកា ការពិនិត្យនិងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ។

ប្រធាន**រ.ប.ស.ក.**ត្រូវជ្រើសរើសមន្ត្រីម្នាក់នៃ**រ.ប.ស.ក.** ជាលេខាធិការនៃអង្គប្រជុំ។ លេខាធិការនេះពុំមានសិទ្ធិបោះឆ្នោតទេ។

ក្រុមប្រឹក្សាភិបាលធ្វើការពិភាក្សាលើរបៀបវារៈដែលបានគ្រោង។ របៀបវារៈត្រូវជូនដំណឹងមុនយ៉ាងតិច១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាលនិងសមាជិកពាក់ព័ន្ធដទៃផ្សេងទៀត។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលមានចែងក្នុងមាត្រា៤២នៃព្រះរាជក្រឹត្យនេះ ត្រូវចូលរួមក្នុងសម័យប្រជុំ

របស់ក្រុមប្រឹក្សាភិបាល តែពុំមានសិទ្ធិបោះឆ្នោតទេ។

ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាល លើសពី ៥០(ហាសិប)ភាគរយ។ សមាជិករបស់ក្រុមប្រឹក្សាភិបាលអវត្តមានពុំអាចឱ្យគេជំនួសបានឡើយ។

ប្រសិនបើកូរ៉ុមពុំបានគ្រប់គ្រាន់នោះ ប្រធានក្រុមប្រឹក្សាភិបាលអាចកោះអញ្ជើញប្រជុំជាថ្មីក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃក្រោយ។ ការប្រជុំលើកក្រោយនេះមិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈដែលខកខានពុំបានប្រជុំតាមការអញ្ជើញលើកទី១(មួយ)ប៉ុណ្ណោះ។

សមាជិកដែលចូលរួមប្រជុំត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវអនុម័តតាមមតិភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខារបស់ប្រធាននិងរក្សាទុកនៅទីស្នាក់ការរបស់**រ.ប.ស.ភ.**។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវកត់ត្រាក្នុងកំណត់ហេតុ។ កំណត់ហេតុត្រូវឆ្លុះបញ្ចាំងពីភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ។ លេខាធិការនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលត្រូវរៀបចំនិងធ្វើសេចក្តីព្រាងកំណត់ហេតុជូនសមាជិកក្រុមប្រឹក្សាភិបាលក្នុងរយៈពេល២(ពីរ)ថ្ងៃក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំនីមួយៗ។ សមាជិកក្រុមប្រឹក្សាភិបាលមានរយៈពេល៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទទទួលបានកំណត់ហេតុប្រជុំដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវឬផ្តល់មតិកែសម្រួលលើកំណត់ហេតុ។ ក្នុងរយៈពេល១០(ដប់)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំ ប្រធានក្រុមប្រឹក្សាភិបាលចុះហត្ថលេខាលើកំណត់ហេតុដែលទទួលបានការកែតម្រូវឬការយល់ព្រមពីសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់។

កំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាលនិងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលខាងលើត្រូវបញ្ជូនក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំ ជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់និងជូនសមាជិកអង្គប្រជុំ។

ការប្រជុំសាមញ្ញប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំត្រូវធ្វើឡើងជាចាំបាច់ដោយមិនត្រូវឆ្លងខែបន្ទាប់នៃដំណាច់ត្រីមាស ឆមាស និងឆ្នាំ។ ការខកខានមិនបានប្រជុំក្រុមប្រឹក្សាភិបាល ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំគឺជាការទទួលខុសត្រូវផ្ទាល់របស់ប្រធានក្រុមប្រឹក្សាភិបាល។

## ផ្នែកទី២
## អង្គភាពប្រតិបត្តិរបស់រ.ប.ស.ភ.

**មាត្រា១៨ .-**

**រ.ប.ស.ភ.**ត្រូវគ្រប់គ្រងដោយប្រធានដែលត្រូវបានតែងតាំងនិងបញ្ចប់មុខតំណែងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី។ ប្រធាន**រ.ប.ស.ភ.**ត្រូវជ្រើសរើសចេញពីក្នុងចំណោមសមាជិកពេញសិទ្ធិនៃ**រ.ប.ស.ភ.**។ ប្រធាន**រ.ប.ស.ភ.**មានតួនាទីជាប្រធានអង្គភាពប្រតិបត្តិនៃ**រ.ប.ស.ភ.**។ ការតែងតាំងប្រធាន**រ.ប.ស.ភ.**ត្រូវធ្វើឡើងយ៉ាងយូរ១(មួយ)ខែ ក្រោយពីការចូលជាធរមាននៃព្រះរាជក្រឹត្យនេះ។

មុខងារនៃប្រធាន**រ.ប.ស.ភ.**មានវិសមិតភាពជាមួយមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា និងជាមួយមុខងារជាប្រធានក្រុមប្រឹក្សាភិបាល។ យ៉ាងយូរ ១(មួយ)ខែ ក្រោយ

ការតែងតាំង ប្រធាន**រ.ប.ស.ភ.**ត្រូវចាត់ចែងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យនិងសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូង។

**មាត្រា១៩ .-**

ប្រធាន**រ.ប.ស.ភ.**ជាតំណាងរបស់**រ.ប.ស.ភ.** ក្នុងការទាក់ទងជាមួយនឹងតតិយជន។

ប្រធាន**រ.ប.ស.ភ.**បំពេញមុខងារនិងមានភារកិច្ច ដូចតទៅ៖

- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំផែនការអភិវឌ្ឍន៍**រ.ប.ស.ភ.** ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់**រ.ប.ស.ភ.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់**រ.ប.ស.ភ.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- រៀបចំរបាយការណ៍គ្រប់គ្រង របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈរបស់**រ.ប.ស.ភ.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ដែលស្ថិតក្រោមការកាន់កាប់និងប្រើប្រាស់របស់**រ.ប.ស.ភ.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- បញ្ជូនបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតម្កល់ទុកនិងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ធ្វើការបញ្ជាក់ ក្នុងករណីចាំបាច់នូវភារកិច្ចដែលត្រូវបានប្រគល់ជូនអង្គភាពចំណុះនានានៃ**រ.ប.ស.ភ.**
- លើកសំណើរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ការកំណត់មុខងារ ក្របខ័ណ្ឌ និងចំនួនមន្ត្រីរាជការនិងបុគ្គលិករបស់**រ.ប.ស.ភ.** ជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- លើកសំណើសុំលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗសម្រាប់បុគ្គលិកគ្រប់ប្រភេទជូនក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត
- គ្រប់គ្រងនិងអនុវត្តកិច្ចលទ្ធកម្មសាធារណៈដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈជាធរមាន
- បំពេញមុខងាររដ្ឋបាលនិងគ្រប់គ្រងទាំងឡាយដទៃទៀតដែលត្រូវបានប្រគល់ឱ្យស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

ប្រធាន**រ.ប.ស.ភ.**មានសិទ្ធិស្នើទៅទីស្តីការគណៈរដ្ឋមន្ត្រីសុំតែងតាំងអនុប្រធានមួយរូបឬច្រើនរូបដើម្បីជួយភារកិច្ចតាមការចាំបាច់។ អនុប្រធានទី១ត្រូវជាសមាជិកពេញសិទ្ធិនៃ**រ.ប.ស.ភ.**។

អនុប្រធានត្រូវមានសញ្ញាបត្របណ្ឌិតឡើងទៅនិងត្រូវមានចំណេះដឹងលើផ្នែកបច្ចេកទេសតាមវិស័យនីមួយៗដែលត្រូវទទួលគ្រប់គ្រង។

**មាត្រា២០ .-**

ការរៀបចំនិងការប្រព្រឹត្តទៅនៃ**រ.ប.ស.ភ.**ត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៣
## បុគ្គលិករបស់រ.ប.ស.ភ.

**មាត្រា២១ .-**

បុគ្គលិកអចិន្ត្រៃយ៍របស់**រ.ប.ស.ភ.**គឺជាមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈដែលត្រូវបានតែងតាំងឱ្យបម្រើការងារនៅក្នុង**រ.ប.ស.ភ.** ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មន្ត្រីរាជការ**រ.ប.ស.ភ.**ដែលមានស្នាដៃល្អក្នុងកិច្ចការស្រាវជ្រាវត្រូវវាយតម្លៃជ្រើសរើសបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីស្រាវជ្រាវ។

លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីស្រាវជ្រាវត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

**រ.ប.ស.ភ.**អាចត្រូវបានអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ខ្លួន ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បុគ្គលិករបស់**រ.ប.ស.ភ.**ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាផ្ទៃក្នុងដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

ចំពោះមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ បទបញ្ជាផ្ទៃក្នុងស្តីពីបុគ្គលិកត្រូវអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត របស់មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ។

មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈដែលបំពេញការកិច្ចនៅ**រ.ប.ស.ភ.**ទទួលបានការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗពីថវិការដ្ឋស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗពីថវិការដ្ឋ ជូនបុគ្គលិកអចិន្ត្រៃយ៍និងបុគ្គលិកជាប់កិច្ចសន្យានៃ**រ.ប.ស.ភ.**ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ប្រធាន**រ.ប.ស.ភ.** បន្ទាប់ពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។

## ផ្នែកទី៤
## ទ្រព្យសម្បត្តិរបស់រ.ប.ស.ភ.

**មាត្រា២២ .-**

**រ.ប.ស.ភ.**ត្រូវទទួលខុសត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមលក្ខខណ្ឌកំណត់ដោយច្បាប់និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

ទ្រព្យសម្បត្តិរបស់**រ.ប.ស.ភ.** រួមមាន៖

- ធនធានគ្រាដំបូងទទួលបានពីរដ្ឋដែលមានបញ្ជាក់ក្នុងតារាងតុល្យការភ្ជាប់ជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យស្តីពីការបង្កើត**រ.ប.ស.ភ.** ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។ តារាងតុល្យការនៃធនធានគ្រាដំបូងនេះត្រូវរៀបចំដោយគណៈកម្មការអន្តរក្រសួង រវាងទីស្តីការគណៈរដ្ឋមន្ត្រីនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវទទួលបានការឯកភាពពីអាណាព្យាបាលទាំងពីរ។ តារាងតុល្យការត្រូវមានភ្ជាប់នូវបញ្ជីសារពើភណ្ឌទ្រព្យ

សម្បត្តិរដ្ឋ រួមជាមួយនឹងតារាងឧបសម្ព័ន្ធពាក់ព័ន្ធនានា។

ខ- ទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលអាចរកបានក្រោយថ្ងៃបង្កើត**រ.ប.ស.ក.** ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

**រ.ប.ស.ក.**ត្រូវបង្កើតគណៈកម្មការមួយមានឈ្មោះថាគណៈកម្មការរៀបចំបញ្ជីសារពើភណ្ឌ ដើម្បីរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់**រ.ប.ស.ក.**។ ប្រធាន**រ.ប.ស.ក.** ដែលជាប្រធាននិងសមាជិកដទៃទៀតនៃគណៈកម្មការនេះត្រូវទទួលខុសត្រូវនិងចុះហត្ថលេខាលើបញ្ជីសារពើភណ្ឌដែលបានរៀបចំរួច។ ការរៀបចំបញ្ជីសារពើភណ្ឌត្រូវបំពេញទិន្នន័យរបស់ទ្រព្យសម្បត្តិនីមួយៗឱ្យបានពេញលេញនិងគ្រប់ជ្រុងជ្រោយ ដោយអនុលោមទៅតាមបែបបទ នីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**រ.ប.ស.ក.**មានភារកិច្ចរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋ កើនឡើងនិងថយចុះ ប្រចាំឆ្នាំនីមួយៗឱ្យបានត្រឹមត្រូវ ដោយយកបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋភ្ជាប់នឹងតារាងតុល្យការនៃធនធានគ្រាដំបូងជាគោល រួចហើយត្រូវផ្ញើមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ(ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)យ៉ាងយូរនៅក្នុងត្រីមាសទី១នៃឆ្នាំបន្ទាប់។

**រ.ប.ស.ក.**អាចធ្វើការទិញ លក់ ដូរ ជួល ផ្ទេរ និងធ្វើការជម្រះបញ្ជីចលនទ្រព្យនិងអចលនទ្រព្យលុះត្រាតែទ្រព្យសម្បត្តិទាំងនោះ ត្រូវបានចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ។ លក្ខខណ្ឌនិងនីតិវិធីនៃការទិញ លក់ ដូរ ជួល ផ្ទេរ និងធ្វើការជម្រះបញ្ជីនូវទ្រព្យសម្បត្តិរដ្ឋទាំងនោះ ត្រូវស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ ហើយត្រូវស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ក្នុងករណីដែល**រ.ប.ស.ក.**ត្រូវធ្វើការរំលាយ លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយព្រះរាជក្រឹត្យ ទ្រព្យសកម្មដែលជាចលនទ្រព្យនិងអចលនទ្រព្យរបស់**រ.ប.ស.ក.**ត្រូវបង្វិលចូលជាកម្មសិទ្ធិរបស់រដ្ឋវិញ ក្រោយពីការជម្រះបញ្ជីតាមនីតិវិធីជាធរមាន។ ចំពោះទ្រព្យសកម្មជារូបិយវត្ថុត្រូវបង្វែរចូលគណនីទោលរបស់ធនាគារជាតិ។

## ផ្នែកទី៥
## ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យរបស់រ.ប.ស.ក.

### មាត្រា២៣ .-

**រ.ប.ស.ក.**ត្រូវមានគណនេយ្យភាពចំពោះទីស្តីការគណៈរដ្ឋមន្ត្រីនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

### មាត្រា២៤ .-

ប្រធាន**រ.ប.ស.ក.**ជាអាណាប័កផ្ទេរសិទ្ធិនៃថវិការបស់**រ.ប.ស.ក.**ដែលទទួលបានការប្រគល់សិទ្ធិពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីដែលជាអាណាប័កដើមខ្សែ ដោយមានសិទ្ធិអំណាច ដូចតទៅ៖

- អនុម័តនិងជម្រះចំណូល
- អនុញ្ញាតចំណាយ ជម្រះបញ្ជី និងចេញអាណត្តិបើកប្រាក់។

ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ ប្រធាន**រ.ប.ស.ក.**អាចផ្ទេរសិទ្ធិនេះបន្តឱ្យអាណាប័កជំនួស ដោយមាន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS

ការយល់ព្រមពីអាណាប័កដើមខ្សែ។

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីត្រូវតែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់**រ.ប.ស.ភ.** តាមសំណើរបស់ប្រធាន**រ.ប.ស.ភ.** និងដោយមានការសម្រេចជាមុនពីក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុនៅ**រ.ប.ស.ភ.**។ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម៖

- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្រឡើងផ្នែកសេដ្ឋកិច្ចឬផ្នែកហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ចឬផ្នែកហិរញ្ញវត្ថុយ៉ាងតិច៣(បី)ឆ្នាំ
- ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៥ .-**

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងការកាន់កាប់បញ្ជីគណនេយ្យ ត្រូវអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។

គណនេយ្យករត្រូវមានគុណវុឌ្ឍិនិងបទពិសោធន៍វិជ្ជាជីវៈច្បាស់លាស់ គ្រប់គ្រាន់ ព្រមទាំងបំពេញលក្ខខណ្ឌផ្សេងទៀតដែលស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ គណនេយ្យករត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គណនេយ្យករត្រូវចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់។ គណនេយ្យករ មានភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រងការប្រមូលចំណូល
- ទូទាត់ចំណាយ
- រក្សាទុកនិងគ្រប់គ្រងការប្រើប្រាស់នូវមូលនិធិនិងវត្ថុមានតម្លៃ
- រក្សាទុកនូវលិខិតយុត្តិការនិងកាន់កាប់បញ្ជីគណនេយ្យ
- ចូលរួមរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់**រ.ប.ស.ភ.**។

គណនេយ្យករអាចមានមន្ត្រីជំនាញមួយចំនួនជាជំនួយការក្នុងការបំពេញមុខងាររបស់ខ្លួន។

**មាត្រា២៦ .-**

ប្រភពធនធានរបស់**រ.ប.ស.ភ.** រួមមាន៖

- ធនធានដំបូងរបស់រដ្ឋផ្តល់ជូន**រ.ប.ស.ភ.** នៅពេលចាប់ផ្តើមបង្កើតដំបូងស្របតាមមាត្រា២២ នៃព្រះរាជក្រឹត្យនេះ
- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈដែលមានគ្រោងក្នុងថវិកាជាតិរដ្ឋ ដូចជាឧបត្ថម្ភធនសម្រាប់ដំណើរការនិងឧបត្ថម្ភកធនជាមូលធនអំណោយ ជំនួយ និងអច្ច័យទានដែល**រ.ប.ស.ភ.** បានទទួល
- កម្រៃសេវាសាធារណៈឬភាគទានដែល**រ.ប.ស.ភ.**មានសិទ្ធិប្រមូលដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- កម្រៃពីទ្រព្យសម្បត្តិរបស់**រ.ប.ស.ភ.** និងចំណូលពីការលក់ទ្រព្យសម្បត្តិទាំងនោះស្របតាមការកំណត់នៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

- ចំណូលផ្ទាល់ឬចំណូលស្របច្បាប់ផ្សេងៗ។

**មាត្រា២៧ .-**

ចំណូល ចំណាយចរន្ត និងមូលធនរបស់**រ.ម.ស.ភ.**ត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់**រ.ម.ស.ភ.** និងត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិការបស់ទីស្ដីការគណៈរដ្ឋមន្ត្រី។ ចំណូលរបស់**រ.ម.ស.ភ.** រួមមានការឧបត្ថម្ភពីថវិការដ្ឋ ចំណូលផ្ទាល់ និងចំណូលផ្សេងៗ ស្របតាមមាត្រា២៦នៃព្រះរាជក្រឹត្យនេះ។

ថវិកាត្រូវរៀបចំដោយប្រធាន**រ.ម.ស.ភ.** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដើម្បីពិនិត្យនិងអនុម័ត រួចបញ្ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រីពិនិត្យនិងសម្រេច មុននឹងបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយអនុលោមតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ដូចមានចែងក្នុងច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

ថវិកាត្រូវមានតុល្យភាពរវាងចំណូលនិងចំណាយ។

ចំណូលនិងចំណាយរបស់**រ.ម.ស.ភ.**ត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់និងការគ្រប់គ្រងដូចថវិកាជាតិដែរ។

ចំណាយត្រូវឆ្លុះបញ្ចាំងនូវគ្រប់មុខសញ្ញានៃការប្រើប្រាស់ពីគ្រប់ប្រភពឥណទាន។

**រ.ម.ស.ភ.**មិនអាចបង្កើតលក្ខខណ្ឌដែលនាំឱ្យមានឱនភាពថវិកាឡើយ ក្នុងអំឡុងពេលនៃការអនុវត្តថវិកាប្រចាំឆ្នាំ លើកលែងតែមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៨ .-**

គណនេយ្យរបស់**រ.ម.ស.ភ.** រួមមាន៖

- គណនេយ្យទូទៅដែលគោរពតាមគោលការណ៍ទ្វេភាគដែលឆ្លុះបញ្ចាំងគ្រប់ប្រតិបត្តិការថវិកា ប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការជាមួយតតិយជន
- គណនេយ្យអចលនទ្រព្យ ទ្រព្យសកម្ម និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើមានការចាំបាច់។

កិច្ចបញ្ជិកាគណនេយ្យរបស់**រ.ម.ស.ភ.**ត្រូវរៀបចំស្របតាមវិធានទូទៅនិងប្លង់គណនេយ្យសាធារណៈ។

គោលការណ៍ណែនាំស្ដីពីកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យរដ្ឋទេយ្យបុរេប្រទាន និងគណនេយ្យរដ្ឋទេយ្យចំណូលរបស់**រ.ម.ស.ភ.**ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៩ .-**

ថវិការបស់**រ.ម.ស.ភ.**គឺជាមូលនិធិសាធារណៈរបស់រដ្ឋ។

ថវិការបស់**រ.ម.ស.ភ.**ដែលមានប្រភពឧបត្ថម្ភធនពីថវិការដ្ឋត្រូវដាក់ចូលក្នុងគណនីនៅរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចអនុញ្ញាតឱ្យ**រ.ម.ស.ភ.**ប្រើប្រាស់គណនីនៅធនាគារពាណិជ្ជសម្រាប់គ្រប់គ្រងថវិកាដែលបានមកពីចំណូលផ្ទាល់និងពីប្រភពផ្សេងៗទៀត។

អតិរេករបស់**រ.ម.ស.ភ.**ត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល។ អតិរេកនេះត្រូវមានការបញ្ជាក់ទទួលស្គាល់ពីទីស្ដីការគណៈរដ្ឋមន្ត្រីនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អតិរេកនេះអាចត្រូវបានចាត់ចែងសម្រាប់ធ្វើហិរញ្ញប្បទានដល់ចំណាយប្រតិបត្តិការនាការិយបរិច្ឆេទបន្ទាប់ និង/ឬសម្រាប់ការវិនិយោគជាប្រយោជន៍ដល់ការអភិវឌ្ឍ**រ.ម.ស.ភ.** ឬជាកម្មវត្ថុនៃការបង់ចូលថវិកាជាតិ។

ការចាត់ចែងអតិរេកនេះត្រូវមានការយល់ព្រមពីទីស្តីការគណៈរដ្ឋមន្ត្រីនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៦
## របបសារពើពន្ធរបស់រ.ប.ស.ភ.

**មាត្រា៣០ .-**

**រ.ប.ស.ភ.**ត្រូវស្ថិតនៅក្រោមនីតិវិធីនៃរបបសារពើពន្ធជាធរមាន លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់។

## ផ្នែកទី៧
## ការងារលទ្ធកម្មរបស់រ.ប.ស.ភ.

**មាត្រា៣១ .-**

ការគ្រប់គ្រង ការអនុវត្ត និងការត្រួតពិនិត្យការងារលទ្ធកម្មក្នុង**រ.ប.ស.ភ.**ត្រូវអនុលោមតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៤
## អាណាព្យាបាលភាព

**មាត្រា៣២ .-**

**រ.ប.ស.ភ.**មានអាណាព្យាបាលពីរ ដូចខាងក្រោម៖

១- អាណាព្យាបាលបច្ចេកទេស គឺទីស្តីការគណៈរដ្ឋមន្ត្រី។

២- អាណាព្យាបាលហិរញ្ញវត្ថុ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានអគ្គនាយកដ្ឋានថវិកាជាសេនាធិការក្នុងការសម្របសម្រួលគ្រប់គ្រង។

**មាត្រា៣៣ .-**

អាណាព្យាបាលបច្ចេកទេសនិងអាណាព្យាបាលហិរញ្ញវត្ថុ អាចចាត់មន្ត្រីមានសមត្ថកិច្ចឱ្យធ្វើអធិការកិច្ចសវនកម្ម តាមដាន និងត្រួតពិនិត្យលើកិច្ចប្រតិបត្តិការនានារបស់**រ.ប.ស.ភ.** តាមការចាំបាច់។

**មាត្រា៣៤ .-**

**រ.ប.ស.ភ.**ត្រូវផ្តល់ជូនអាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំ**រ.ប.ស.ភ.** ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ ក្រោយការពិនិត្យនិងអនុម័តដោយក្រុមប្រឹក្សាភិបាលនូវឯកសារ ដូចខាងក្រោម៖

- កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍន៍**រ.ប.ស.ភ.**
- គម្រោងថវិកាប្រចាំឆ្នាំរបស់**រ.ប.ស.ភ.**
- របាយការណ៍គ្រប់គ្រងរដ្ឋបាល របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ របាយការណ៍លទ្ធកម្មសាធារណៈ និងរបាយការណ៍ហិរញ្ញវត្ថុរបស់**រ.ប.ស.ភ.**។

បន្ទាប់ពីទទួលបានឯកសារខាងលើ អាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំ**រ.ប.ស.ភ.**ត្រូវចាត់ការបន្តតាមសមត្ថកិច្ចរៀងៗខ្លួន ស្របតាមបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី១
## អាណាព្យាបាលបច្ចេកទេស

**មាត្រា៣៥ .-**

អាណាព្យាបាលបច្ចេកទេសមានភារកិច្ច ដូចខាងក្រោម៖

- កំណត់គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់**រ.ប.ស.ក.** អនុវត្ត
- ពិនិត្យនិងសម្រេចផែនការអភិវឌ្ឍន៍របស់**រ.ប.ស.ក.**
- ពិនិត្យនិងសម្រេចលើសេចក្តីព្រាងនៃគម្រោងថវិកាប្រចាំឆ្នាំរបស់**រ.ប.ស.ក.**
- ពិនិត្យនិងសម្រេចលើសំណើចាត់ចែង ប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងជម្រះបញ្ជីសារពើភណ្ឌ
- ត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលនៃការអនុវត្តផ្នែកបច្ចេកទេសរបស់**រ.ប.ស.ក.**
- ដាក់ចេញនូវវិធានការកែលម្អនានាពាក់ព័ន្ធនឹងការអនុវត្តផ្នែកបច្ចេកទេសរបស់**រ.ប.ស.ក.**
- ពិនិត្យនិងសម្រេចអំពីរចនាសម្ព័ន្ធនៃ**រ.ប.ស.ក.**
- ស្នើតែងតាំងប្រធាន**រ.ប.ស.ក.**
- តែងតាំងមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈដែលបម្រើការងារនៅ**រ.ប.ស.ក.** អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- តែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់**រ.ប.ស.ក.**។

**មាត្រា៣៦ .-**

អនុលោមតាមបទប្បញ្ញត្តិជាធរមាន អាណាព្យាបាលបច្ចេកទេសត្រូវផ្ញើជូនអាណាព្យាបាលហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរ នូវការសម្រេចទាំងឡាយរបស់ខ្លួននិងរបស់ក្រុមប្រឹក្សាភិបាលដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរដ្ឋ ដើម្បីពិនិត្យនិងសម្រេច ដូចខាងក្រោម៖

- ផែនការអភិវឌ្ឍន៍**រ.ប.ស.ក.**
- គម្រោងថវិកាប្រចាំឆ្នាំរបស់**រ.ប.ស.ក.**
- ការចាត់ចែង ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងការជម្រះបញ្ជីសារពើភណ្ឌ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- សេចក្តីសម្រេចស្តីពីការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ
- សេចក្តីសម្រេចផ្សេងទៀតដែលអាចមានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ។

**មាត្រា៣៧ .-**

អាណាព្យាបាលបច្ចេកទេសមានសិទ្ធិលុបឬផ្អាកការអនុវត្តសេចក្តីសម្រេចពាក់ព័ន្ធនឹង**រ.ប.ស.ក.** ក្នុងករណីដែល៖

- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលឬប្រធាន**រ.ប.ស.ក.** ផ្ទុយនឹងគោលនយោបាយឬយុទ្ធសាស្ត្ររបស់**រ.ប.ស.ក.** ក៏ដូចជារបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលឬប្រធាន**រ.ប.ស.ក.** ផ្ទុយនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សេចក្តីសម្រេចធ្វើឡើងដោយក្រសួង ស្ថាប័ន អាជ្ញាធរដែលមិនមានសមត្ថកិច្ចតាមផ្លូវច្បាប់ឬសេចក្តីសម្រេចធ្វើឡើងដោយការប្រជុំក្រុមប្រឹក្សាភិបាលដែលពុំអនុលោមតាមនីតិវិធី
- សេចក្តីសម្រេចមានការពាក់ព័ន្ធនឹងបណ្តឹងផ្សេងៗ ដែលពុំទាន់បានដោះស្រាយរួច។

ការលុបចោលឬការផ្អាកខាងលើនេះ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានបញ្ជាក់ពីមូលហេតុច្បាស់លាស់។ ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវជូនដំណឹងអំពីប្រកាសនេះដល់ប្រធាន**រ.ម.ស.ភ.**។ ប្រធាន**រ.ម.ស.ភ.**ត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា៣៨ .-**

ក្នុងករណីដែលក្រុមប្រឹក្សាភិបាលឬប្រធាន**រ.ម.ស.ភ.**ពុំប្រតិបត្តិតាមបណ្តាវិធានដែលមានចែងក្នុងច្បាប់ឬបទប្បញ្ញត្តិនិងបទបញ្ជាផ្ទៃក្នុងរបស់**រ.ម.ស.ភ.** ទីស្តីការគណៈរដ្ឋមន្ត្រីអាចចេញសេចក្តីសម្រេចនិងអាចប្រើប្រាស់វិធានការចាំបាច់ទាំងអស់ បន្ទាប់ពីបានធ្វើការណែនាំនិងដាក់កំហិតជាលាយលក្ខណ៍អក្សររួចមក។

## ផ្នែកទី២
## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា៣៩ .-**

អាណាព្យាបាលហិរញ្ញវត្ថុមានភារកិច្ចៈ

- ពិនិត្យនិងផ្តល់ការយល់ព្រមលើផែនការអភិវឌ្ឍន៍**រ.ម.ស.ភ.**
- ពិនិត្យនិងសម្រេចលើគម្រោងថវិកាប្រចាំឆ្នាំរបស់**រ.ម.ស.ភ.**
- ពិនិត្យនិងអនុម័តផែនការលទ្ធកម្មរបស់**រ.ម.ស.ភ.**
- ពិនិត្យនិងសម្រេចលើការចាត់ចែង ប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងការជម្រះបញ្ជីសារពើភណ្ឌ
- ពិនិត្យនិងផ្តល់ការយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ពិនិត្យនិងសម្រេចលើសេចក្តីសម្រេចស្តីពីការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ
- ពិនិត្យនិងសម្រេចឬផ្តល់ការយល់ព្រមលើឯកសារផ្សេងទៀត តាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រីឬប្រធាន**រ.ម.ស.ភ.** ស្របតាមបទប្បញ្ញត្តិជាធរមាន
- រៀបចំនិងដាក់ឱ្យអនុវត្តនូវវិធាននិងនីតិវិធីចំណូល ចំណាយ បទដ្ឋានចំណូល ចំណាយ និងបទដ្ឋានគតិយុត្តទាំងឡាយដទៃទៀតពាក់ព័ន្ធនឹងហិរញ្ញវត្ថុរបស់**រ.ម.ស.ភ.**។

**មាត្រា៤០ .-**

សេចក្តីសម្រេចរបស់ប្រធាន**រ.ម.ស.ភ.**របស់ក្រុមប្រឹក្សាភិបាល និងរបស់អាណាព្យាបាលបច្ចេកទេសដែលពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា៣៩នៃព្រះរាជក្រឹត្យនេះ ពុំមានអានុភាពអនុវត្តឡើយក្នុងករណីដែលពុំមានការយល់ព្រមពីអាណាព្យាបាលហិរញ្ញវត្ថុ។

ក្នុងករណីអាណាព្យាបាលហិរញ្ញវត្ថុជំទាស់លើសេចក្តីសម្រេច ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ អាណាព្យាបាលហិរញ្ញវត្ថុ ត្រូវផ្ញើជូនអាណាព្យាបាលបច្ចេកទេសនិងប្រធាន**រ.ម.ស.ភ.**នូវការជំទាស់របស់ខ្លួន ដោយបញ្ជាក់នូវមូលហេតុច្បាស់លាស់។ ប្រធាន**រ.ម.ស.ភ.** ក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេស ត្រូវពិនិត្យនិងដោះស្រាយឱ្យបានឆាប់បំផុត នូវករណីដែលបានលើកឡើងនោះដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៤១ .-**

អាណាព្យាបាលហិរញ្ញវត្ថុអាចលុបឬផ្អាកការអនុវត្តសេចក្តីសម្រេចចិត្តពាក់ព័ន្ធទិដ្ឋភាពហិរញ្ញវត្ថុរបស់ប្រធាន**រ.ម.ស.ភ.** ក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេស ក្នុងករណីដែលៈ

- សេចក្តីសម្រេចរបស់ប្រធាន**រ.ម.ស.ភ.** របស់ក្រុមប្រឹក្សាភិបាល និងរបស់អាណាព្យាបាល

បច្ចេកទេស ផ្ទុយនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

- សេចក្ដីសម្រេចមានការពាក់ព័ន្ធនឹងបណ្ដឹងផ្សេងៗដែលពុំទាន់បានដោះស្រាយរួច។

ការលុបចោលឬការផ្អាកទុកនេះ ត្រូវមានបញ្ជាក់ពីមូលហេតុច្បាស់លាស់និងត្រូវជូនដំណឹងដល់អាណាព្យាបាលបច្ចេកទេសនិងប្រធាន**រ.ប.ស.ក.**ដែលត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា៤២ .-**

អាណាព្យាបាលហិរញ្ញវត្ថុត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ១(មួយ)រូបប្រចាំ**រ.ប.ស.ក.** ដើម្បីបំពេញមុខងារ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៥
## ការត្រួតពិនិត្យ

**មាត្រា៤៣ .-**

**រ.ប.ស.ក.**ត្រូវមានអង្គភាពសវនកម្មផ្ទៃក្នុងដែលត្រូវបង្កើត តែងតាំង ផ្លាស់ប្ដូរ និងបញ្ចប់ភារកិច្ចដោយអាណាព្យាបាលបច្ចេកទេស តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

**មាត្រា៤៤ .-**

**រ.ប.ស.ក.**ត្រូវស្ថិតក្រោមការធ្វើអធិការកិច្ច សវនកម្ម តាមដានត្រួតពិនិត្យ ដោយអាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ ស្របតាមច្បាប់ជាធរមាន។

ក្នុងករណីចាំបាច់ **រ.ប.ស.ក.**អាចត្រូវបានតម្រូវឱ្យស្ថិតក្រោមការធ្វើសវនកម្ម ដោយសវនករឯករាជ្យដោយមានការទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា៤៥ .-**

លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការបង្កើតនិងការរៀបចំនិងការប្រព្រឹត្តទៅនៃ**រ.ប.ស.ក.**ត្រូវមានអានុភាពអនុវត្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា៤៦ .-**

ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៨៨៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលមាត្រា៦នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា១០ថ្មី មាត្រា១១ថ្មី មាត្រា១២ថ្មី និងមាត្រា២០ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៧ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១៩

ន សីហមុនី

៣៧៣.១៦១២.១៩៥៥

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**